# ទៅស្ទូចត្រី

*ហេដិនមានចិត្តអន្ទះសារចង់ទៅស្ទូចត្រី ! ប្រសិនបើ ដាន់មិនបានមកជាមួយនោះ មិនដឹងល្អយ៉ាងណាទេ ។ . . .*

**ដោយ យូលី វិនទូរ៉ា**
ផ្អែកទៅលើដំណើររឿងពិត

*« ខ្ញុំមានក្រុមគ្រួសារលើផែនដី ។ គេផ្ដល់ក្ដីសុខដល់ខ្ញុំ »* ( សៀវភៅចម្រៀងកុមារ *លេខ ៤៥* ) ។

« តោះ ចូរយើងយកឧបករណ៍ស្ទូចត្រី ។ ដល់ពេលស្ទូចត្រីហើយ ! » ឪពុកបាននិយាយ ។

ហេដិនបានញញឹមពេលគាត់ក្រឡេកមើលជុំវិញខ្លួន ។ អ្វីគ្រប់យ៉ាងមានភាពស្រស់បំព្រង និង មានភាពរីករាយ ។ មានតែពួកគេទេដែលទៅបឹងនោះ !

ហេដិនបានដើរតាមប៉ាទៅក្រោយឡាន ហើយលើកប្រអប់ឧបករណ៍ស្ទូចត្រីចេញពីខ្លុបឡាន ។ វាធ្ងន់ណាស់ ប៉ុន្តែគាត់មិនត្អូញទេ ។ គាត់អាចយួររបស់ធ្ងន់ៗបែបនោះ ម្ដងពីរក៏បានដែរឲ្យតែបានមកស្ទូចត្រីជាមួយប៉ា ។

ដងសន្ទូចប៉ះកកិតគ្នានៅពេលប៉ាបានទាញវាចេញមក ។ គាត់និយាយថា « មើលទៅដាន់ដូចជាងងុយដេក ។ តើកូនដាស់វាបានទេ ? »

ហេដិនព្យាយាមមិនដកដង្ហើមធំ ។

« បាទ បាន » ។

គាត់ស្ទើរតែភ្លេចថាប្អូនប្រុសគាត់ ដាន់ក៏បានមកផងដែរ ។ ដាន់តែងតែរត់លេង ហើយនិយាយព្ទៗ ។ គាត់បានធ្វើឲ្យត្រីផ្អើលអស់ !

គាត់បានមើលតាមកញ្ចក់ទ្វារឡាន ។ « ដាន់ក្រោកឡើង » ។

ប៉ុន្តែដាន់នៅតែដេកនៅឡើយ ។

ហេដិនឈប់បន្តិច ។ ដោយក្ដីសង្ឃឹមថា ដាន់អាចដេករហូតដល់ត្រឡប់ទៅផ្ទះវិញ ។

ហេដិនងាកទៅទាញប្រអប់ដាក់ឧបករណ៍ស្ទូចត្រីដោយស្ងាត់ៗ យកទៅកន្លែងប៉ាស្ទូចត្រីនៅឯមាត់បឹង ។

« នេះគឺជានុយ រួមទាំងដង្កូវផង ! »

ប៉ាបានយកប្រអប់ដាក់ឧបករណ៍ស្ទូចត្រីពីគាត់ ។ « ល្អណាស់ អរគុណ » ។ ក្រោយមកប៉ាបានងាកមើលជុំវិញខ្លួន ។ « តើប្អូនឯងនៅឯណា ? »

ហេដិនបានក្រឡេកមើលទៅឡាន ។ គាត់បានឆ្ងល់ក្នុងចិត្តថា តើ *ប្អូនគាត់* មានអារម្មណ៍បែបណាពេលគាត់បានដឹងខ្លួនឡើងហើយនៅតែឯងនាកន្លែងថ្មីនេះ ។ ហេដិនមានអារម្មណ៍មិនល្អឡើយ ។ ប្រាកដណាស់ គាត់ប្រហែលជាភ័យខ្លាំងណាស់ហើយ ។ ហើយដាន់មានអាយុតែប្រាំឆ្នាំប៉ុណ្ណោះ ។

« ចាំមួយភ្លែត ប៉ា ។ ខ្ញុំនឹងត្រឡប់មកវិញ » ។ ប៉ុន្តែនៅពេលគាត់មើលទៅក្នុងឡាន អត់ឃើញដាន់ទេ !

ហេដិនមិនអាចស្ដាប់ឮសំឡេងសត្វល្អិតអ្វីទៀតឡើយ ។ អ្វីគ្រប់យ៉ាងហាក់ដូចជាស្ងាត់ស្ងៀម ។

« ដាន់អត់នៅក្នុងឡានទេ ! » ហេដិនបានស្រែក ។

ប៉ាបានមកយ៉ាងលឿនហើយមើលនៅក្នុងឡាន ។

ប៉ាបាននិយាយថា « វាប្រហែលជាកំពុងរកពួកយើងហើយ » ។ « វាគ្រាន់តែមួយភ្លែតសោះ ។ វាមិនទាន់ទៅណាឆ្ងាយទេ »។

ហេដិនបានព្យាយាមធ្វើឲ្យចិត្តស្ងប់ ប៉ុន្តែគាត់ភ័យបុកពោះ ។ « តើខ្ញុំអាចអធិស្ឋានបានទេ ? »

« ប៉ាគិតថា នេះជាគំនិតល្អណាស់ » ។

ហេដិនបានអរព្រះគុណដល់ព្រះវរបិតាសួគ៌សម្រាប់ប្អូនប្រុសរបស់គាត់ ហើយទូលសុំឲ្យពួកគេអាចរកដាន់ឃើញភ្លាម ដើម្បីកុំឲ្យគាត់ភ័យខ្លាច ។

ពេលហេដិនបានបញ្ចប់ការអធិស្ឋាន គាត់ឈប់មានចិត្តតានតឹង ។

ប៉ាបានដាក់ដៃលើស្មារបស់ហេដិន ។ « ចុះប្រសិនបើកូនជាដាន់វិញ តើកូនមានអារម្មណ៍ដូចម្ដេច ? តើកូននឹងទៅណា ? »

ហេដិនបានឃើញថាទ្វារឡានម្ខាងទៀតបានបើក ។ ដាន់ប្រហែលជាមិនបានឃើញពួកគេនៅឯមាត់បឹង ។ ហេដិនបានចង្អុលទៅស្នាមដានជើងនៅក្បែរនោះ ។ គាត់បាននិយាយថា « ខ្ញុំប្រហែលជាចាប់ផ្ដើមដើរតាមផ្លូវនេះ » ។

ពួកគេបានប្រញាប់ដើរតាមស្នាមដានជើងនោះ ។

យើងហាក់បីដូចជាដើរយឺតណាស់ ។ នៅពេលគាត់ដើរ ហេដិនបានបន្តអធិស្ឋានក្នុងចិត្តគាត់ ។

បន្ទាប់ពីដើរបានមួយសន្ទុះមក ពួកគេបានដើរតាមស្នាមដានជើងនោះមកដល់កៅអីវែង ហើយបានឃើញ ដាន់នៅពីមុខពួកគេ ។

« ដាន់ ! » ហេដិនបានស្រែក ។

ដាន់បានបែរមក ហើយញញឹម ។ « ហេ៎ តើប៉ានិងបងនាំគ្នាទៅណា ? »

ដល់ពេលរីករាយវិញហើយ ។ ហេដិនបានរត់ទៅរកដាន់ ហើយឱបគាត់យ៉ាងណែន ។

ហេដិនបាននិយាយថា « បងរីករាយណាស់ដែលរកឃើញប្អូនវិញ » ។ គាត់បានអធិស្ឋានថ្លែងក្នុងចិត្តរបស់គាត់ភ្លាមដើម្បីថ្លែងអំណរគុណ ។

ដាន់បានញញឹម ។ « តើត្រីនៅឯណា ? »

ហេដិនបាននិយាយថា « មកនេះបងនឹងឲ្យប្អូនមើល » ។ គាត់រត់យ៉ាងអន្ទះសាទៅមាត់បឹង ។ « ឥឡូវនេះចាំមើលថានរណាចាប់បានត្រីមុនគេ ។ ខ្ញុំនឹងជួយបិទនុយសន្ទូចឲ្យបង » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ ចចចារ ស.រ.អា. ។*

